# រឿង មហាចោរនៅទល់ដែន

## ភាគទី២៨

សានក៏ស្ទុះ ទៅលើកជណ្ដើរផ្ទះរបស់អ្នកស្រុកម្នាក់ យកមកផ្អែកលើទ្វារ។ នាយសានឡើងជណ្ដើរភ្លាម ឥតបង្អង់។ លុះមកដល់លើទ្វារហើយ នាយសានក៏បែរគូទ ទម្លាក់ជើងទាំងពីរចុះ ដៃទាំងពីរចាប់ខ្លោងទ្វារ ធ្វើឲ្យនាយសាន ធូន់ខ្លួនយើងយោង។

នាយកោប ដែលលិទ្ធអណ្ដាត រង់ចាំចំណី ដល់បានឃើញខ្មាំងមកដូច្នោះ ក៏ស្ទុះរឹងទៅកាប់មួយដាវចំពីក្រោយ ត្រង់គល់ក ។ នាយសានលាន់សម្លេង ព្ធឹក រួចធ្លាក់ខ្លោកដល់ដី។

និលពេជ្រ ដែលនៅខាងក្រៅនឹកថា នាយសានបានដល់ដីហើយ រួចមុខជាមកបើកទ្វារមិនខាន តែចាំបាត់ៗ៖ និលពេជ្រខ្សឹបហៅ៖

- សាន ! សាន ! ទៅណាបាត់អន្តរធាននេះ អាធីទៅមួយទៀតបន្តគ្នាទៅ។

នាយធីដឹកមុខឡើងជណ្ដើរ ដល់ចុង ក៏វាត់ជើងស្ទុះចុះមក។ ក្នុងពេលនោះ ដាវអគ្គីលៀនចេញឆ្ពោ ពីគុម្ពផ្កាមក តែនាយធីវាយរង់ដាវទាន់ ដាវទាំងពីរក៏ប្រកួតគ្នាព្ធាំងៗ ដូចរន្ទះកណ្ដាលយប់ស្ងាត់។ ពួកខាងនិលពេជ្រស្រែកថា «មានពួកវាអើយ !» ។ លំដាប់នោះ នាយទាហាន ក៏ជ្រុះមកក្នុងរបងផ្ទះនាយគី ខ្លោកៗ បន្តបន្ទាប់គ្នា ដូចគ្រាប់ភ្លៀង។ នាយកោប និងអគ្គី តយុទ្ធម៉ាំងៗ យ៉ាងអង់អាច។ និលពេជ្រមកដល់ក្រោយគេ បញ្ជាឲ្យឈប់។

- ឈប់ ! អ្នកណាហ្នឹង ?

អគ្គីឆ្លើយថា៖

- អញ!
- អឺ ! គីទេឬ ?
- អឺ ! អញ ម៉េចនិលទេឬ ? ឯងមកលេងនឹងអញឬ ?
- អឺអញៗ មកលេង!
- បើមកលេង មកកុំបង្អង់ !

អត្ថបទដោយ៖ មាស សុភាព

- ឯងមកមានការអីទាំងយប់ ? (អគ្គីសួរបន្ថែម)
- អញមកជាតំណាងច្បាប់។

នាយកោបចេញពីគុម្ពផ្កាមក សើចក្អាកក្អាយ៖

- ហាសៗ តំណាងច្បាប់ ! មានតែចោរទេ ដែលចូលក្នុងរបងផ្ទះគេ ដោយលបៗ ។ អ្នកតំណាងច្បាប់ មិនធ្វើដូច្នោះទេ។
- យី ! អាកោប អញមកនេះមានសំបុត្រ។
- ចាំភ្លឺស្រួលបួលទៅពូ ! មានអី។
- អាកោប អញមិនខ្ជិលនិយាយនឹងឯងទេ។

និលស្ទុះទៅមុខ ក្អែកមើលទៅក្នុងផ្ទះ ។ អគ្គីលើកដាវកាប់ រាំងដើមទ្រូងនិលពេជ្រ។

- មិនបានទេ ! មិត្តទៅណាមកណា ទៅមិនបាន។
- អញទៅក្នុងផ្ទះ។
- ប្ដូនឬ ?
- អញចាប់មនុស្សទោស។
- គ្មានមនុស្សទោសទេ នៅនេះមានតែអ្នកជាទាំងអស់។
- មាន ។
- ទៅមិនបាន ទៅស្លាប់ឯង ឬ ស្លាប់អញ !
- ព្រះកម្ពុតឲ្យអញមកណ៎ា។
- ទេវតាឲ្យមកក៏ត្រូវឈប់ ដ្បិតអគ្គីមិនឲ្យចូលទៅ។
- ឯងរឹងទទឹងនឹងច្បាប់ឬ ?
- ឯងរកចាប់អ្នកណា ?
- មានន្ទ !
- ហ៊ីសៗ អាក្រពើ វង្វេងបឹង!

អត្ថបទដោយ៖ មាស សុភាព

- មាននួនៅឯណា?
- នៅនេះ ?
- សម្លេងមាននួលាន់ឮឡើងពីកៅអីមួយ ដែលនៅក្នុងងងឹត។ មាននួដើរស្ទុងៗ ចេញមកយ៉ាងខែង ដៃពត់ចុងដាវតូចស្តើងមួយ ដែលចាំងផ្លេកៗ។
- រកខ្ញុំធ្វើអី ?
- ក្នុងនាមនៃច្បាប់ ខ្ញុំសូមចាប់ សូមអញ្ជើញអានសំបុត្រនេះទៅចុះ ។

មាននួកញ្ឆក់សំបុត្រ ពីដៃនិលពេជ្របាន ញីហែកខ្ទេចខ្ទី គ្រវាត់ចោលទៅ។ និលពេជ្រខឹងខ្នួលឡើង។

- យី ! ម៉េចព្រះតេជគុណ ហ៊ានហែកសំបុត្រព្រះកម្ពុត ?
- ខ្វាចអី សំបុត្រមិនត្រឹមត្រូវតាមច្បាប់។
- មិនមែនទេ ! បោះត្រាលោកផងណា!
- អើ! ត្រាមែន តែសំបុត្ររំលោភ ឲ្យចាប់យើងទាំងយប់ គ្មានច្បាប់ណាឲ្យចាប់ដូចនេះទេ។
- អាកូន ! ចូលចាប់ !

មាននួថយក្រោយបីជំហាន គ្រវាសដាវ និយាយយ៉ាងសង្ហាថា៖

- ចាប់មាននួបាន លុះត្រាតែធ្លាក់អាវុធពីដៃ។

នាយកោប និង នាយគី ក៏ថ្វៃងសកម្មភាពជំនាលគ្នា ដាវលាន់ឮឆាំងៗ ចែសៗ ឡើងពីពោះដូចសូរនោតដែកៗ បី ទល់នឹងពីរ ជាទីគួរដែរ។ មាននួវាយផ្ទងៗ ពីរបីដាវ ស្ទុះទៅកាប់អាម្នាក់នៅចំហៀងខាង ដួលប្រប្រោងដើង បាត់ស្មារតី រួចស្រែកថា៖

- មួយហើយវើយ !

មាននួវាយថយ រត់ទៅគេច នឹងគល់ឈើ ដែលធ្វើឲ្យខាងនិលពេជ្រវិលមុខៗ ដោយងងឹតផង អ្នកតជាប់ដៃ ចុងដាវសត្រូវ ខ្វែងខ្វាត់ ប្រវាត់គ្នា ច្រុះនឹងចុងដាវអ្នកៗ មាននួគេចទៅពួនឯគល់ឈើមួយទៀត។ ខាងនិលពេជ្រ រកមិនឃើញ វេវៗ មាននួស្រែកហៅ ថា៖

អត្ថបទដោយ៖ មាស សុភាព

- ឯនេះទេវើយ ! មក !

កងនិលពេជ្ររត់ទៅ មានន្ទគេចទៅម្ខាង វាយខ្នងនាយធីផ្ទង មួយដាវអស់ទំហឹង ដែលនាំឲ្យធីក័យជាអនេក។ ដល់ដឹងថា មានន្ទ ក៏ស្ទុះហក់ដេញ តាមប្រកិត ។ ចំនែកខាងនាយកោប និង អគ្គី ក៏បង្កើតបរិយាកាសកំប្លែងលេង លាយមែនដូចគ្នា។ យូរៗ នាយកោប បែរទៅសើចដាក់អគ្គីម្តង។ មានន្ទញញឹមយ៉ាងរីករាយ នឹងស្ថានការណ៍រីករាយនេះ។ លុះចេញដល់ក្រៅរបង ជនទាំងបី ចេះតែវាយថយ រហូតទៅដល់នឹងហ្វូងសេះ របស់កងនិលពេជ្រ ដែលចងតម្រៀបគ្នា។ មានន្ទបញ្ជាយ៉ាងខ្លាំង ថា៖

- ឡើងសេះ !

នាយកោប និង អគ្គីរហ័សដូចស្វរ ដល់លើខ្នងសេះជាស្រេច ក៏បំផាយសេះទៅ ដោយមានជនខាងនិលពេជ្រ ដេញជាប់ពីក្រោយ។ រីឯមានន្ទ កាលស្រែកបញ្ជា ស្ទុះរឹងក្លាមដែរ តែទាក់ជើងនឹងកូនឈើមួយ ដួលព្រួស។ មានន្ទរមៀលខ្លួន បណ្តោយដូចផ្លែក្រូច រួចក្រោកឈររើបវិញ តដៃទៅទៀតយ៉ាងអង់អាច។ និលពេជ្រស្ទុះមករាំងផ្លូវ មិនឲ្យមានន្ទឡើងសេះរួច ។ និលពេជ្របញ្ជា ឲ្យទាហានម្នាក់ លែងខ្សែសេះ ឲ្យរត់ទៅឆ្ងាយពីទីនោះ។ តែមានន្ទទាត់ត្រូវមួយជើង ដួលផ្កាប់មុខ ដោយមិនដឹងខ្លួន។ កងខាងនិលពេជ្រ រោមមានន្ទដូចស្រមោច ប៉ុន្តែផ្សិតតែមានខ្វះ ត្រូវរបួសច្រើនអន្លើ ណាស់ទៅហើយ។ មានន្ទគេចខ្លួនបាន ក៏លោតលើខ្នងសេះបំផាយទៅ។ និលពេជ្រក៏បញ្ជា ឲ្យកងពលឡើងសេះតាមទៅដែរ។ មានន្ទ រត់ឆ្ពងអូរ ឆ្ពងជ្រោះ យ៉ាងលឿន ។ និលពេជ្រព្យាយាមតាមជាប់ពីក្រោយ មិនឈប់ឈរ។

ព្រះអរុណ រះស្វាងឡើង ។ សេះមានន្ទ កាន់តែដាបទៅៗ រីឯខ្មាំង កាន់តែជិតមកៗ។ មានន្ទមើលឃើញទាំងអស់ មានប្រាំមួយនាក់ ។ អ្នកនឹកថា តើគេចខ្លួនយ៉ាងណា ឲ្យរួចទាន់ភ្លឺមិនទាន់ច្បាស់នេះ។ ដល់ដើមអំពិលមួយ អ្នកលោតទៅចាប់មែកអំពិល តោងឡើងទៅពួននៅស្ងៀម។ សេះដោយក័យចេះរត់ទៅមុខ ។ កងនិលពេជ្រ ចេះតែដេញតាមប្រកៀក។ មានន្ទមើលពីក្រោយ ឃើញហុយធូប អ្នកសើចយោលខ្លួន រួចចុះមកគេចទៅខាងជើង។ ទៅតាមផ្លូវអ្នកដោះឡេវអាវផ្ដុំខ្យល់ ដកដង្ហើមវែងៗ ឲ្យមានកម្លាំង។ មាណពនឹកថា ខ្យល់ព្យុះ មុខជាផុត

អត្ថបទដោយ៖ មាស សុភាព

រលត់មិនខាន។ អ្នកដើរបណ្ដើរ ហួចបណ្ដើរ បីដូចអ្នកគង្វាលគោម្នាក់ ដែលគ្មានដឹងឮ ដល់រឿងអ្វីសំខាន់ឡើយ។ បុរសចេះតែក្រលេកមើលក្រោយ ម្ដងៗ ក្រែងខ្មាំងដេញតាមមកទៀត។ អ្នកសម្លឹងមើលព្រៃឈើរកនឹក «តើជាព្រៃភូមិណា ស្រុកណា?» ។ ពន្លឺព្រះអាទិត្យ ក៏ឡើងថ្លាត្រចង់ គួរជាទីសប្បាយ។ តាមផ្លូវដើមរុក្ខជាតិធំ តូច ដុះណែនណាន់ តាន់តាប់ ខ្ពស់ទាប។ អ្នកនឹកថា ស្រុកខ្មែរ ជាស្រុកមានភោគទ្រព្យក្រៃពេក ពុំគួរនៅក្រោមអំនាចខ្មាំងសោះ។ អ្នកនឹកទៀតថា «ពួកនិលពេជ្រ ស្លាប់ថ្ងៃនេះ ក៏ក្រែលដែរ គឺខ្មាំងស្លាប់ នឹងដៃអ្នកជាច្រើន អ្នកមិនខាតទេក្នុងម្ដេមួយម៉ោងចុងក្រោយនេះ។

សត្វកុក ដែលនៅប្របផ្លូវ ពួនសម្ងំចឹកត្រី ក្នុងថ្លុកមួយ ផ្អើលឈូហើរឡើង។ មានទន្សាក់ព្រើត ក្រាបពួន តែដល់មិនឃើញអ្វី ក៏ដើរទៅមុខទៀត។ អុញទុំ៖! ឃើញវាលស្រែទេតើ។ មានអ្វី? មានទន្សាញញឹមគិតថា «ឱ! ភូមិកុយមែនទេតើ» អ្នកបែរសសៀរ យកជើងព្រៃ។ លុះដល់ផ្ទះមួយ ដែលនៅចុងភូមិ អ្នកឡើងភ្លាម ចូលទៅក្នុងបន្ទប់បិទទ្វារបាត់៕

(សូមរង់ចាំតាមដានភាគទី២៩ នៅសប្ដាហ៍ក្រោយ)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព